**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ០២.០៥៧/០៨ គ.ជ.ប.អគ្គ.៣ស** ភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨

# សន្និសីទសារព័ត៌មាន : ផ្សព្វផ្សាយបញ្ជីបោះឆ្នោតផ្លូវការ និងការផ្តល់អនុសាសន៍ ដែលទាក់ទងនឹងសេចក្តីព្រាងបទបញ្ជា និងនីតិវិធី

នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ គ.ជ.ប បានធ្វើសន្និសីទសារព័ត៌មានមួយផ្សព្វផ្សាយអំពីបញ្ជីបោះឆ្នោតផ្លូវការ និងចំនួនអង្គការ ស្ថាប័នដែលបានផ្តល់មតិយោបល់ទាក់ទងនឹងសេចក្តីព្រាងបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ឆ្នាំ ២០០៨ ។

ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា គ.ជ.ប បានពិនិត្យ និងអនុម័តលើបញ្ជីបោះឆ្នោតរួចរាល់ហើយកាលពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។ បញ្ជីបោះឆ្នោតនេះមានឈ្មោះអ្នកបោះឆ្នោតសរុបចំនួន ៨.១២៤.០៩២ នាក់ ។ ឯកឧត្តមបានបញ្ជាក់ថា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ នេះ មានការិយាល័យបោះឆ្នោតសរុបចំនួន ១៥.២៥៤ ការិយាល័យ ។

ទាក់ទងនឹងមតិយោបល់ដែលអង្គការ ស្ថាប័នបានផ្តល់មតិយោបល់ដើម្បីចូលរួមក្នុងសេចក្តីព្រាងបទបញ្ជា និងនីតិវិធី ឯកឧត្តម អ៊ឹម សួស្តី បានមានប្រសាសន៍ថា មានក្រសួងមហាផ្ទៃ គណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សនរោត្តម រណឫទ្ធិ គណបក្សសិទ្ធិមនុស្ស និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២ គឺខុមហ្វ្រែល និងនិកហ្វិច ។

នៅក្នុងសន្និសីទនោះដែរ តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលបានស្នើសុំឱ្យ គ.ជ.ប រៀបចំកិច្ចប្រជុំមួយជាមួយស្ថាប័នពាក់ព័ន្ធដែលបានផ្តល់អនុសាសន៍ទាក់ទងនឹងសេចក្តីព្រាងបទបញ្ជា និងនីតិវិធី មុននឹង គ.ជ.ប អនុម័ត ។

ឯកឧត្តមប្រធាន គ.ជ.ប បានជម្រាបជូនថា គ.ជ.ប នឹងរៀបចំឱ្យមានកិច្ចប្រជុំមួយរវាងថ្នាក់អគ្គលេខាធិការដ្ឋានជាមួយនឹងតំណាងអង្គការ ស្ថាប័នដែលបានផ្តល់ជាមតិយោបល់ទាក់ទងនឹងសេចក្តីព្រាងបទបញ្ជា និងនីតិវិធីនេះ ដើម្បីធ្វើការពន្យល់ឱ្យបានច្បាស់អំពីចំណុចនៃមតិយោបល់ដែល គ.ជ.ប មិនបានដាក់បញ្ចូលក្នុងសេចក្តីព្រាងនោះ ។

ក្នុងសន្និសីទនោះដែរ តំណាងគណបក្សនយោបាយបានស្នើសុំឱ្យ គ.ជ.ប ឈប់ប្រើប្រាស់ទម្រង់ ១០១៨ ហើយសុំឱ្យ គ.ជ.ប ជួយជំរុញដល់ក្រសួងមហាផ្ទៃ ចេញនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋឱ្យបានលឿនដើម្បីធ្វើជាឯកសារសម្រាប់យកទៅបោះឆ្នោត ។

ឯកឧត្តម អ៊ឹម សួស្តី បានបញ្ជាក់យ៉ាងច្បាស់ទាក់ទងនឹងទម្រង់១០១៨ នេះ ថា " យើងមិនអាចឈប់ប្រើទម្រង់នេះបានទេ ពីព្រោះអ្នកមានអត្តសញ្ញាណប័ណ្ណពេលខ្លះគាត់អាចបាត់ ឧទាហរណ៍ ភ្លើងឆេះផ្ទះ លិចទូក... តើគាត់មានឯកសារអ្វីដើម្បីយកទៅបោះឆ្នោត" ។ ឯកឧត្តមបានបន្ថែមថា សម្រាប់ការបោះឆ្នោតជាតិ គ.ជ.ប មានគម្រោងណែនាំឱ្យមេឃុំ ចៅសង្កាត់បញ្ឈប់ការចេញទម្រង់ ១០១៨ នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត ។

BtmanbEnmsmTnakTngTrsBe I x³ 023 214 374 / 012 855 018 E-mail: necinfo@forum.org.kh, Web-site : www.necelect.org.kh